*សូមទ្រង់ជ្រាបក្រោមល្អងធូលីព្រះបាទ*

*ក្នុងឱកាសដ៏នក្ខត្តឫក្ស ដែលព្រះអង្គទ្រង់បានទទួលព្រះរាជកេតនភណ្ឌជាសម្តេចព្រះសំឃរាជថ្នាក់ទី ១ នេះ*

*ទូលព្រះបង្គំទាំងឡាយជាសមាជិកនៃគណៈកម្មាធិការនាយកសមាគមសាស្ត្រាចារ្យខ្មែរ តាងនាមសមាជិកខ្លួនទាំងប្រាំបីរយនាក់ មានកិត្តិយសនឹងសេចក្តីរីករាយជាពន់ពេកនឹងសូមព្រះរាជានុញ្ញាតក្រាបបង្គំទូលថ្វាយព្រះអង្គនូវសេចក្តីកោតសរសើរ នឹងសេចក្តីសោមនស្សសាទររបស់ខ្លួនដោយអស់ពីដួងចិត្ត ។*

*ក្នុងឱកាសនេះ ទូលព្រះបង្គំទាំងឡាយសូមប្រសិទ្ធិថ្វាយព្រះអង្គ នូវពរមហាជោគជ័យសិរីមង្គលវិបុលសុខ សូមព្រះអង្គទ្រង់មានព្រះជន្មាយុយឺនយូរពប់ជាងរយព្រះវស្សា ដើម្បីទ្រង់បានជាម្លប់ដល់កូនចៅពុទ្ធសាសនិកទាំង ៦ លាននាក់ ក្នុងការគ្រាប់លើមាគ៌ាបង្រួបបង្រួមជាតិ ឧបត្ថម្ភព្រះពុទ្ធសាសនា នឹង កសាងជាតិ ឆ្ពោះទៅរកវឌ្ឍនភាព ដូចអារ្យប្រទេសនានា ។*

សេចក្តីគួរពុំគួរ សូមទ្រង់ព្រះមេត្តាប្រោស
សូមក្រាបបង្គំទូលថ្វាយ

*ភ្នំពេញ នៅថ្ងៃ ២៦ ធ្នូ ១៩៦៤*

*ទូលព្រះបង្គំជាខ្ញុំ:*

អ៊ឹម សាវឿន

*អនុប្រធាន*

★ ◙ ★

★ មិត្តយើងបានជ្រាបក្នុងលេខមុនស្រាប់ហើយថា ក្នុងឱកាសដែលអ្នកអង្គម្ចាស់ ស៊ីសុវត្ថិ សិរិមតៈ ទ្រង់បានយាងមកកាន់មន្ទីរអប់រំជាតិ និង វិចិត្រសិល្បៈ ស. ស. ខ. បានផ្ញើលិខិតមួយច្បាប់ថ្វាយទ្រង់ ដើម្បីនឹងសំដែងនូវសេចក្តីសរសើរ ហើយនឹងសេចក្តីរាប់រងចំពោះទ្រង់ អំពី « វិភាគទានតាមសមត្ថភាពយ៉ាងសកម្មនិងយ៉ាងសុធន្ទះរបស់ ស. ស. ខ. ក្នុងការធ្វើឲ្យសិក្សាធិការជាតិលូតលាស់ទៅមុខ និងបានល្អប្រសើរ . . . » ។

សមាគមសាស្ត្រាចារ្យខ្មែរ — ភ្នំពេញ, ថ្ងៃ ២១ ឧសភា ១៩៦៤

លេខ ១២៣ E វិថីព្រះសីហនុ — ប្រធាននៃគណៈកម្មាធិការនាយក

ភ្នំពេញ

សូមក្រាបបង្គំទូលអ្នកអង្គម្ចាស់ ទេសរដ្ឋមន្ត្រីទទួលបន្ទុកខាងការអប់រំជាតិ និង វិចិត្រសិល្បៈ

ភ្នំពេញ

អ្នកអង្គម្ចាស់,

ក្នុងនាមនៃសាស្ត្រាចារ្យទាំងប្រាំបីរយនាក់ជាសមាជិក ក្នុងនាមនៃគណៈកម្មាធិការនាយក និងក្នុងនាមផ្ទាល់នៃទូលព្រះបង្គំ ទូលព្រះបង្គំមានសេចក្តីសោមនស្សសាទរជាពន់ពេក ចំពោះព្រះរាជហឫទ័យនៃសម្តេចឪដែលព្រះអង្គទ្រង់តែងតាំងអ្នកអង្គម្ចាស់ជាទេសរដ្ឋមន្ត្រីខាងការអប់រំ ហើយទូលព្រះបង្គំសូមសំដែងនូវសេចក្តីសរសើរដោយគោរពយ៉ាងជ្រាលជ្រៅជាទីបំផុតថ្វាយទ្រង់ចំពោះព្រះតំណែងថ្មីនេះ ។ ក្នុងឱកាសនេះ ទូលព្រះបង្គំសូមព្រះរាជានុញ្ញាតធានាប៉ារ៉ង់ដល់ទ្រង់ថា ក្នុងពេលនេះក៏ដូចជានៅក្នុងអតីតកាល សមាគមសាស្ត្រាចារ្យខ្មែរត្រៀមខ្លួនជានិច្ច ដើម្បីនឹងធ្វើវិភាគទានតាមសមត្ថភាពរបស់ខ្លួនយ៉ាងសកម្មនិងយ៉ាងសុធន្ទៈ ក្នុងការធ្វើឲ្យសិក្សាធិការជាតិលូតលាស់ទៅមុខនិងបានល្អប្រសើរ ជាពិសេសក្នុងការធ្វើឲ្យបានសំរេចនូវព្រះរាជតំរាយនៃសម្តេចឪដ៏ជាទីស្នេហាក្នុងវិស័យកែទំរង់ការសិក្សាជាតិ ។

សូមអ្នកអង្គម្ចាស់ទទួលនូវសេចក្តីគោរពដ៏ស្មោះស្ម័គ្រនៃទូលព្រះបង្គំ ។

សេចក្តីគួរពុំគួរ សូមទ្រង់មេត្តាប្រោស

កែ សុខន

★ ចំពោះលិខិតខាងលើរបស់ ស. ស. ១. អ្នកអង្គម្ចាស់ទេសរដ្ឋមន្ត្រីទទួលបន្ទុកខាងក្រសួងអប់រំជាតិ និង វិចិត្រសិល្បៈ ទ្រង់បានសព្វព្រះហឫទ័យឆ្លើយតបវិញ កាលពីថ្ងៃ ២៨ ឧសភា ១៩៦៤ ដូចតទៅ :

ព្រះរាជាណាចក្រកម្ពុជា — ភ្នំពេញ ថ្ងៃទី ២៨ ខែ ឧសភា គ. ស. ១៩៦៤

ទីស្តីការរដ្ឋមន្ត្រី ក្រសួងសិក្សាធិការ
លេខ ២៣៥៣ ល – ធ

ទេសរដ្ឋមន្ត្រីទទួលបន្ទុក ខាងក្រសួងអប់រំជាតិ និង វិចិត្រសិល្បៈ

ជំរាបសហជីវិនប្រធានគណៈកម្មាធិការនាយក នៃសមាគមសាស្ត្រាចារ្យខ្មែរ
លេខ ១២៣ E វិថីព្រះសីហនុ

ក្រុងភ្នំពេញ

**កម្មវត្ថុ:** សេចក្តីថ្លែងអំណរគុណ

**យោង:** លិខិតសហជីវិន ចុះថ្ងៃទី ២១ ឧសភា ១៩៦៤

តបនឹងលិខិតដែលយោងខាងលើនេះ ខ្ញុំមានហឫទ័យសោមនស្សរីករាយយ៉ាងក្រៃលែង ហើយសូមថ្លែងនូវសេចក្តីត្រេកអររបស់ខ្ញុំជាអនេកប្បការ ចំពោះសេចក្តីជានារ៉ាប់រងរបស់សមាគមសាស្ត្រាចារ្យខ្មែរដែលបានថ្វាយចំពោះខ្ញុំ នៅឱកាសដែលខ្ញុំបានទទួលដំណែងជាទេសរដ្ឋមន្ត្រីទទួលបន្ទុកខាងក្រសួងអប់រំជាតិ និងវិចិត្រសិល្បៈនេះ ។

សូមសហជីវិនទទួលនូវសេចក្តីរាប់អានអំពីខ្ញុំ ។

ស៊ីសុវត្ថិ សិរិមតៈ

◙

3

## មិត្តទាំងឡាយ,

អត្ថបទដែលមិត្តមានបំណងនឹងផ្ញើមកចុះក្នុងលេខក្រោយ
សូមមិត្តរៀបចំចាប់ពីឥឡូវនេះឲ្យហើយទៅ!

★ ក្នុងឱកាសដែល សម្តេចឪ ទ្រង់ស្តេចយាងទៅព្យាបាលព្រះរោគ នឹង បំពេញព្រះរាជទស្សនកិច្ចផ្លូវរដ្ឋនៅប្រទេសបារាំងលើកនេះ ស. ស. ខ. បានរួបរួមជាមួយ នឹង ប្រជាជាតិទាំងមូល ដើម្បីនឹងប្រសិទ្ធថ្វាយព្រះអង្គនូវសព្ទសាធុការពរមហាជោគជ័យសិរីមង្គលវិបុលសុខ ចំពោះព្រះសុខភាពព្រះអង្គ នឹង ចំពោះព្រះរាជទស្សនកិច្ចព្រះអង្គ.

## សេចក្តីថ្វាយព្រះពរ

### សូមព្រះតេជៈតំកល់លើត្បូង

### សូមក្រាបបង្គំទូលថ្វាយសម្តេចឪព្រះប្រមុខរដ្ឋ

### សូមទ្រង់ជ្រាបក្រោមល្អងធូលីព្រះបាទ

ដោយបានដឹងតាមព្រះសារលិខិតដែលសម្តេចឪទ្រង់បានសព្វព្រះរាជហឫទ័យផ្ញើមកថ្វាយព្រះមហាក្សត្រិយានីព្រះមាតាជាតិ ថាអន្តរាគមន៍ពេទ្យជាលើកដំបូងបានប្រព្រឹត្តទៅប្រកបដោយជោគជ័យ ហើយថាព្រះសុខភាពរបស់ព្រះអង្គ បានចំរើនប្រសើរឡើងជាលំដាប់ហើយ ;

ដោយបានដឹងតាមសារពត៌មាននានាថា ព្រះកិច្ចសន្ទនាជាលើកដំបូងរបស់ព្រះអង្គជាមួយនឹងលោកឧត្តមសេនីយ ដឺហ្គោល បានជួបនឹងការសំរេចផលយ៉ាងប្រសើរ ក្នុងក្របខណ្ឌនៃការស្វែងរកប្រយោជន៍ជូនជាតិ និងជូនសន្តិភាពសាកលលោក ជាពិសេសក្នុងពេលដែលអាស៊ីអាគ្នេយ៍កំពុងតែឆ្លងកាត់កាលៈទេសៈមួយ ប្រកបដោយគ្រោះថ្នាក់នេះ ;

ហើយដោយជឿជាក់ថា ជោគជ័យនៃព្រះទស្សនកិច្ចផ្លូវរដ្ឋនេះ ដែលនឹងមានកិត្តិសព្ទរន្ទឺខ្ទរខ្ទារយ៉ាងគគ្រឹកគគ្រេងដូចនេះបាន ក៏ដោយសារតែព្រះគតិបណ្ឌិតដ៏ភ្លឺថ្លា នឹងព្រះបញ្ញាញាណដ៏មុតមុះរបស់ព្រះអង្គ ;

ទូលព្រះបង្គំទាំងឡាយជាសមាជិកគណៈកម្មាធិការនាយកនៃសមាគមសាស្ត្រាចារ្យខ្មែរ តាងនាមសាស្ត្រាចារ្យជាងប្រាំបីរយនាក់ជាសមាជិករបស់ខ្លួន មានបីតិរីករាយជា

ពន់ពេក ហើយមានអំនួតយ៉ាងក្រៃលែង ដោយមានភព្វសំណាងនឹងបានឋិតនៅក្រោមព្រះកិច្ចមគ្គុទ្ទេសដ៏ឆ្នើមរបស់ព្រះអង្គ ។

ទូលព្រះបង្គំសូមបួងសួងចំពោះវត្ថុសក្តិសិទ្ធិទាំងឡាយ មានទេវតារក្សាព្រះមហាស្វេតច្ឆត្រជាដើម សូមតាមព្យាបាលសម្ដេចឪ សូមព្រះអង្គទ្រង់បានប្រកបទៅដោយព្រះសុខភាពបរិបូរណ៍ឡើងវិញយ៉ាងឆាប់រហ័ស ដើម្បីព្រះអង្គសំរេចបានជាអតិបរមានូវព្រះបេសកកម្មពង្រីកវឌ្ឍន៍មិត្តភាពអន្តរជាតិ ស្ថាបនាសំបូរណភាពជាតិ និងការពារសន្តិភាពសាកលលោក ហើយនឹងយាងនិវត្តមកជាម្លប់ដ៏ត្រជាក់នៃកូនចៅព្រះអង្គវិញ ។

ហើយទូលព្រះបង្គំសូមឆ្លៀតយកឱកាសនេះ ដើម្បីនឹងសំដែងថ្វាយព្រះអង្គជាថ្មីម្ដងទៀត នូវសេចក្ដីស្វាមីភក្ដិរបស់សាស្ត្រាចារ្យខ្មែរជាឯកច្ឆន្ទ ចំពោះព្រះរាជបល្ល័ង្ក ចំពោះព្រះមហាក្សត្រិយានី ចំពោះព្រះអង្គ និងចំពោះព្រះនយោបាយប្រកបដោយគតិបណ្ឌិតរបស់ព្រះអង្គ ព្រមទាំងសេចក្ដីប្ដេជ្ញានឹងតាមដង្ហែព្រះអង្គលុះដល់ទីអវសាន ។

សេចក្ដីគួរពុំគួរ សូមទ្រង់ព្រះមេត្តាប្រោស

សូមក្រាបបង្គំទូលថ្វាយ

ភ្នំពេញ, ថ្ងៃ ២៥ មិថុនា ១៩៦៤

ទូលព្រះបង្គំទាំងឡាយជាសមាជិកគណៈកម្មាធិការនាយក នៃសមាគមសាស្ត្រាចារ្យខ្មែរ

★

**4** សូមមិត្តតំណាងនៅវិទ្យាល័យ - អនុវិទ្យាល័យនិមួយ ៗ មេត្តាផ្ញើមកជូនគណៈកម្មាធិការនាយក ឲ្យបានទៀងទាត់ នូវដំណឹងអំពីសុខទុក្ខនៃមិត្តយើងផង (អាពាហ៍ពិពាហ៍, កូនចៅ, ជម្ងឺឈឺថ្កាត់, គ្រោះថ្នាក់, ការប្រឡងជាប់, ...) ។



សម្តេចព្រះមហាសុមេធាធិបតី (ជួន ណាត)

ព្រះសង្ឃរាជថ្នាក់ទី ១ នៃគណៈមហានិកាយ

# ព្រះភក្រ្តមួយដ៏ផ្តើម នៃ វប្បធម៌ជាតិ

ទីវ អុល, តូប តៅសា

សមាគមសាស្ត្រាចារ្យខ្មែរ សូមលំឱនកាយ វាចា ចិត្ត សំដែងគារវៈភក្តីដ៏ជ្រាលជ្រៅរបស់ខ្លួន ចំពោះសម្តេចព្រះសង្ឃរាជថ្នាក់ទី ១ ដែលទ្រង់បានសព្វព្រះរាជហឫទ័យព្រះរាជានុញ្ញាតឲ្យតំណាងនៃគណៈកម្មាធិការនាយកខ្លួន មិត្តទីវ អុល និង តូប តៅសា ចូលក្រាបបង្គំគាល់ កាលពីថ្ងៃព្រហស្បតិ៍ ២៥ មិថុនា ១៩៦៤ នេះ ដើម្បីនឹងក្រាបបង្គំសូមព្រះរាជដំបូន្មានខ្លះក្នុង «បែបបទកសាងខ្លួនឲ្យបានទៅជាបណ្ឌិត» ទៅជាកុលបុត្រដ៏ផ្តើមនៃប្រជាជាតិយើង ។

◙

សេចក្តីផ្តើមអត្ថបទរបស់យើង ត្រូវតែបិតជាចាំបាច់នៅក្នុងគារវៈភក្តីដ៏ជ្រាលជ្រៅ ហើយនឹងអំណរគុណដ៏ខ្លាំងក្លា ដែលយើងសូមថ្លែងដោយគោរព ថ្វាយសម្តេចព្រះសង្ឃរាជថ្នាក់ទី ១ ដែលទ្រង់បានព្រះរាជានុញ្ញាតឲ្យយើងចូលក្រាបបង្គំគាល់ព្រះអង្គ ដោយព្រះហឫទ័យសាទរជាទីបំផុត ។

គោលបំណងរបស់យើង គឺក្រាបបង្គំសូមព្រះអង្គទ្រង់អធិប្បាយព្រះរាជទាន នូវមហាមាគ៌ាដ៏វែងឆ្ងាយ ដែលដឹកនាំព្រះអង្គឲ្យមកដល់ដំណាក់កាលបច្ចុប្បន្ន ពោរពេញទៅដោយកំរងកែវនៃគតិបណ្ឌិតដ៏ភ្លឺថ្លា ទៅដោយបញ្ញាញាណដ៏វាងវៃនិងទៅដោយស្មារតីស្នេហាជាតិដ៏ទូលំទូលាយ ។

បន្ទាប់ពីទ្រង់បានជ្រាបគោលបំណងរបស់យើង ហើយបន្ទាប់ពីទ្រង់បានថ្លែងព្រះអំណរគុណចំពោះទស្សនាវដ្តីសាស្ត្រាចារ្យ ដែលយើងមានកិត្តិយសនឹងយកទៅថ្វាយហើយ សម្តេចព្រះសង្ឃរាជទ្រង់មានព្រះបន្ទូលថា មាគ៌ាដែលដឹកនាំព្រះអង្គតាំងតែពីអតីតកាលដ៏សាមញ្ញមកដល់បច្ចុប្បន្នកាល ដ៏ក្ងិចក្ងែងចិញ្ចាចនេះមានបណ្តោយវែងឆ្ងាយណាស់ ហើយមិនអាចនឹងយកមកតពណ៌នាតែក្នុងរយៈពេលមួយដ៏ខ្លីបានឡើយ ។ ប៉ុន្តែ ប្រសិនបើគេចង់ស្គាល់មាគ៌ានេះ គេគ្រាន់តែនឹកប៉ុណ្ណោះក៏សឹងតែឃើញខ្លះៗហើយ គឺនឹកថាមាគ៌ាដ៏វែងឆ្ងាយនេះ ពោរពេញទៅដោយការវិតខំព្យាយាមដ៏ស្វិតស្វាញ និងការតស៊ូដ៏មោះមុតព្យាយាមហើយព្យាយាមទៀត តស៊ូហើយតស៊ូទៀត ... ។ ព្រះអង្គគ្រាន់តែទ្រង់មានព្រះបន្ទូលផ្តើមសេចក្តីបានបន្តិច ទ្រង់ក៏ណែនាំឲ្យយើងរង់ចាំទៅក្រោយៗទៀត ដោយលៃពេលឲ្យបានវែងបន្តិច ។ ឯពេលវេលាដែលសល់ក្រៅពីនេះតាំងប៉ុន្មាន (យើងសូមជំរាបថា ការក្រាបបង្គំគាល់នេះប្រព្រឹត្តទៅអស់ដល់ទៅជាងពីរម៉ោងឯណោះ) ព្រះអង្គទ្រង់បានយកមកប្រើដើម្បីនឹងបំភ្លឺ អំពីវិធីប្រើពាក្យខ្លះ ជាពិសេសគឺអាយតនិបាត ដែលសព្វថ្ងៃនេះ បានទទួលការនិយមមិនទាន់មានឯកភាពត្រឹមត្រូវសោះនៅឡើយ ។

■

មែន! មាគ៌ាដ៏វែងឆ្ងាយដែល «ព្រះអភិធជមហារដ្ឋគុរុ»(១) ទ្រង់បានយាងតាមនេះ មិនអាចនឹងយកមកអធិប្បាយឲ្យបានសព្វគ្រប់ក្នុងអត្ថបទមួយដ៏ស្តួចស្តើងដូចនេះទេ ។ ប៉ុន្តែ

---

១– សមណសក្តិ ដែលរដ្ឋាភិបាលភូមាបានថ្វាយក្នុង គ.ស ១៩៥៧; ជាសមណសក្តិខ្ពស់បំផុតនៃសហភាពភូមា ។

ដើម្បីនឹងឲ្យមិត្តយើងមានគំនិតខ្លះៗ អំពីវិសាលភាពនៃវិភាគទាន ដែលព្រះអង្គទ្រង់បានផ្តល់ដល់វប្បធម៌ជាតិ យើងសូមណែនាំមិត្តឲ្យសម្លឹងទៅវចនានុក្រមខ្មែរទាំងពីរភាគ (១៩១៩), កច្ចាយនូបត្ថម្ភកៈ (វេយ្យាករណ៍បាលី មាន ២ ភាគ ១៩២០) គិហិបដិបត្តិ (១៩២៦), សាមណេរវិន័យ (១៩១៧).. និង អត្ថបទជាច្រើនទៀតផ្សាយក្នុងទស្សនាវដ្តីកម្ពុជសុរិយា តាំងពីឆ្នាំ ១៩២៦ រៀងមក ហើយឲ្យមិត្តស្តាប់បទនគររាជដែលយើងតែងតែគោរពរាល់ថ្ងៃនេះ ។ គ្រាន់តែឃើញប៉ុណ្ណោះ ក៏មិត្តអាចនឹងស្គាល់ព្រះសមត្ថភាពបានខ្លះហើយ ប៉ុន្តែស្នាព្រះហស្តនៃព្រះសង្ឃរាជមិនមែនមានត្រឹមស្នាព្រះហស្តសំខាន់ ៗ ទាំងប៉ុន្មានដែលយើងបានពប់មកហើយនេះទេ ។ ទាំងនេះគ្រាន់តែជាស្នាព្រះហស្តក្នុងវិស័យអក្សរសាស្ត្រទេ ឯស្នាព្រះហស្តក្នុងវិស័យសាសនា និងសង្គមកិច្ច មានច្រើនជាងនេះឆ្ងាយទៅទៀត ។ ក្នុងចំណោមស្នាព្រះហស្តទាំងនេះ យើងសូមណែនាំមិត្តឲ្យស្គាល់វត្តពោធិព្រឹក្ស (ឃុំលាំងកែន ស្រុកកណ្តាលស្ទឹង កណ្តាល) – ផ្លូវថ្នល់ ៣ គ.ម. ដែលភ្ជាប់ផ្លូវជាតិនឹងវត្តសុរកើហើយនឹងវត្តពោធិព្រឹក្ស – សាលាបាលីរង ស្ពានធំ ១ នឹងស្ពានតូច ១ ឆ្លងស្ទឹងតូច (ព្រំប្រទល់ឃុំលាំងកែន នឹង ឃុំកោះកោះ) – សាលាបឋមសិក្សាបំពេញវិជ្ជា (សុរកើពោធិព្រឹក្ស) – សាលាសំណាក់ ១ ខ្នង – ស្រះ ១ ទំហំ ១០០ ម៉ែត្រ ៤ ជ្រុង – អណ្តូងយោង ១៦ កន្លែង នឹង អណ្តូងស្នប់ ៣ កន្លែង – មន្ទីរសម្ភព ១ ខ្នង – គិលានដ្ឋាន ១ ខ្នង នឹងគិលានសមណៈ ២ ខ្នង – ទំនប់ទឹក ១ កន្លែងបណ្តោយ ៩០០ ម ទទឹង ៨០០ ម ។

ហើយប្រសិនបើមិត្តចង់ស្គាល់សម្តេចព្រះសង្ឃរាជច្បាស់ថែមទៀត សូមមិត្តជ្រាបថាព្រះបិតានៃវចនានុក្រមខ្មែរ បានប្រសូត្រនៅថ្ងៃអង្គារ (១១ កើត) ខែមីនា ១៨៨៣ នៅភូមិកំរៀង ឃុំកោះកោះ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ។ បិតានាម ជួន មាតានាម យក់ ។ ប្អូនរបស់សម្តេច គឺឧកញ៉ាសោភណមន្ត្រី ជួន ឈុត ។

កាលនៅពីកុមារបានសិក្សាអក្សរនិងលេខ លុះជន្មាយុ១៤ ឆ្នាំ ទើបបួសជាសាមណេរ ក្នុងថ្ងៃ១៥ កើត ខែពិសាខ ( ឧសភា ១៨៩៧ ) នៅវត្តពោធិព្រឹក្ស ។ ក្នុង គ. ស. ១៨៩៩ បានចូលសិក្សាព្រះបរិយត្តិធម៌នៅវត្តឧណ្ណាលោម ហើយដល់ខែមិថុនា ១៩០៤ (ព្រះជន្ម ២១ វស្សា ) បានបំពេញឧបសម្បទាជាភិក្ខុនៅវត្តពោធិព្រឹក្ស ហើយត្រឡប់មកវត្តឧណ្ណាលោមវិញ ;

សម្តេចបានសិក្សាភាសាបាលី ហើយអាចអាននិងសន្ទនាបានដោយឥតទើសទាស់;

សម្តេចចេះអក្សរ ភាសាសៀម លាវយ៉ាងជាក់លាក់ ភាសាបារាំងបានមធ្យម ភាសាអង់គ្លេសខ្លះ និង វៀតណាមខ្លះ ។ គ. ស. ១៩២២ - ២៣ បាននិមន្តទៅបំពេញវិជ្ជាខាងភាសាសំស្ក្រឹត និង អក្សរសិលាចារឹកនៅហាណូយ ;

គ. ស. ១៩១៣ សម្តេចបានប្រឡងដេញប្រយោគបាន ៤ ប្រយោគ ( ខ្ពស់បំផុតក្នុងសម័យនោះ );

គ. ស. ១៩១៥ បានប្រឡងជាប់លេខ ២ ហើយបានទទួលការតែងតាំងជាសាស្ត្រាចារ្យនៅសាលាបាលីជាន់ខ្ពស់ ( ពុទ្ធិកវិទ្យាល័យ ព្រះសុរាម្រឹតសព្វថ្ងៃនេះ );

គ. ស. ១៩១៧ ជាសមាជិកនៃក្រុមជំនុំតែងវចនានុក្រមខ្មែរ ;

គ. ស. ១៩២៧ សម្តេចទ្រង់បានទទួលការតែងតាំងជាសមាជិក នៃក្រុមជំនុំផ្ទៀងសំរេចវចនានុក្រមខ្មែរ ហើយបានទទួលភារៈធ្វើវចនានុក្រមខ្មែរតែមួយព្រះអង្គឯង ដរាបដល់បានចប់សព្វគ្រប់ បោះពុម្ពផ្សាយទាំងភាគមួយ ទាំងភាគពីរ ;

គ. ស. ១៩៣០ ជាចាងហ្វាងនៃសាលាបាលីជាន់ខ្ពស់ក្រុងភ្នំពេញ;

គ. ស ១៩៣៣ សម្តេចទ្រង់បានទទួលការតែងតាំងជាសមាជិក នៃក្រុមជំនុំពិនិត្យសៀវភៅដែលក្រសួងសិក្សាធិការជាតិបោះពុម្ពផ្សាយ ;

គ.ស.១៩៣៥ សម្តេចទ្រង់បានទទួលការតែងតាំងជាសាស្ត្រាចារ្យបង្រៀនភាសា
បាលី សំស្ក្រឹត ខ្មែរ និង លាវ ប្រចាំថ្នាក់ទីបំផុតនៃមធ្យមសិក្សានៅវិទ្យាល័យ ព្រះ
ស៊ីសុវត្ថិ ក្រុងភ្នំពេញ :

គ.ស. ១៩៤២ ជាចាងហ្វាងសាលាបាលីជាន់ខ្ពស់ :

គ.ស. ១៩៤៣ ជាសមាជិកឆ្លើយឆ្លង នៃសាលាបារាំងនៅចុងបូព៌ាប្រទេស
ហើយចាប់ពី ១៩៤៨ ដរាបរៀងមក ជាសមាជិកកិត្តិយសនៃសាលានេះ ;

គ.ស. ១៩៤៤ ជាចៅអធិការវត្តឧណ្ណាលោម :

គ.ស. ១៩៤៥ ជាអធិបតី នៃថេរសភា ( ក្រុមជំនុំសង្ឃជាន់ខ្ពស់ );

គ.ស. ១៩៤៧ ជាអនុប្រធានគណៈកម្មការវប្បធម៌ផ្នែកអក្សរ « ក » នៃគណៈ
កម្មការជាតិខាងការសិក្សា ;

គ.ស. ១៩៤៨ សម្តេចទ្រង់បានទទួលនាទីជាប្រធាននៃគណៈកម្មការធម៌វិន័យ
ពិនិត្យការផ្សាយសៀវភៅសំរាប់សាលាធម៌វិន័យក្នុងព្រះរាជអាណាចក្រ :

ហើយចាប់ពី គ.ស. ១៩៣១ ដល់ ១៩៥៩ សម្តេចទ្រង់បាននិមន្តទៅបំពេញកិច្ច
ការជាច្រើនក្នុងព្រះពុទ្ធសាសនានៅបរទេស មានជាអាទិ៍គឺប្រទេសលាវ ជែនកូស៊ាំង
ស៊ីន លង្កា សហភាពភូមា ឥណ្ឌូណេស៊ី ... ។

▣ បន្ទាប់ពីទ្រង់មានព្រះបន្ទូលអស់រយៈពេលជាង ២ ម៉ោង អំពីព្រះរាជប្រវត្តិ និង អំពីបញ្ហាប្រើពាក្យខ្មែរ
លុះយើងបានក្រាបថ្វាយបង្គំព្រះអង្គ ដោយសូមព្រះរាជទានទោសចំពោះការរំខាននេះហើយ សម្តេចព្រះសង្ឃរាជ
ទ្រង់មានព្រះបន្ទូលថាចំពោះព្រះអង្គ បើនិយាយពីអក្សរសាស្ត្រហើយ គ្មានគិតពីពេលវេលា គ្មានគិតពីសុខកា
អ្វីៗ ឡើយ ហើយទ្រង់បានផ្តែផ្តាំថា ទៅអនាគតបើមានបញ្ហាអ្វីចង់ឲ្យទ្រង់ជួយ ទ្រង់នឹងខិតខំបំពេញតាមព្រះសមត្ថភា
ដោយព្រះហឫទ័យរីករាយជានិរាប ។

▣ យើងសូមថ្លែងនូវអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះព្រះវិន័យមុនីប៊ុណ្យ សុម្ភាគ ដែលបានក្រាប់ទូ
ចងក្រងព្រះរាជប្រវត្តិនៃសម្តេចព្រះសង្ឃរាជ ដែលយើងបានដកស្រង់មកខ្លះ ក្នុងទីនេះ ។

# ដំណឹងមិត្តយើង

▣ កាលពីថ្ងៃអង្គារ ២៣មិថុនា ១៩៦៤ វេលាម៉ោង ១៣ កន្លះ មិត្ត អ៊ឹម សារឿន អនុប្រធានយើង និង ភរិយា បានចេញដំណើរពីចំណតពោធិចិនតុងទៅកាន់ប្រទេសបារាំងតាមអាកាសយាន U.T.A. ។ មិត្តនឹងត្រឡប់មកវិញ ក្នុងពីរខែខាងមុខនេះ ។ បានជូនដំណើរមិត្ត អ៊ឹម សារឿន មានសមាជិកនៃគណៈកម្មាធិការនាយកយើងពីរនាក់ និង ភរិយា តំណាងគណៈកម្មាធិការនាយកនៃសមាគមបុគ្គលិកសិក្សាខ្មែរ ហើយនិងញាតិមិត្តជាច្រើនទៀត ។ យើងសូមបួងសួងឲ្យមិត្ត និង គ្រួសារប្រកបជានិច្ច ទៅដោយសេចក្ដីសុខ និង សេចក្ដីចំរើន ។

▣ មិត្ត (កញ្ញា) សាន សំអាត នៅវិទ្យាល័យព្រះស៊ីហនុ ទើបនឹងបានរៀបអាពាហ៍ពិពាហ៍ជាមួយ និង លោកគ្រូ ជិវ ឆយ នៅសាលារៀនជីហែ ។ អាពាហ៍-វិវាហ៍មង្គល បានប្រព្រឹត្តទៅនៅគេហដ្ឋានមិត្តនារី ក្នុងបរិយាកាសយ៉ាងស្និទ្ធស្នាល និង រីករាយជាទីបំផុត ។ ក្នុងឱកាសនោះ ក្រៅពីញាតិមិត្តខាងគ្រួសារ គេសង្កេតឃើញពីចំណែក ស. ស. ខ. មិត្ត មាស ឌឹម (នាយកវិទ្យាល័យ និង តំណាង ស. ស. ខ. ក្នុងខែត្រកំពង់ចាម) និងសាស្ត្រាចារ្យឯទៀតៗ ជាច្រើន ។ ពីខាងគណៈកម្មាធិការនាយក មិត្តយើងម្នាក់ និង ភរិយាក៏បានទៅចូលរួមប្រស្រ័យក្នុងពិធីដ៏ឧឡារិកនេះដែរ ។

▣ នៅកំពង់ចាមដដែល កាលពីថ្ងៃសៅរ៍ ៣០ ឧសភា ១៩៦៤ មណ្ឌលកីឡាខ្មែរក៏បានជាកសិណនៃអាវាហ៍វិវាហ៍មង្គល របស់មិត្ត ស៊ុន គា សាស្ត្រាចារ្យ (គណិតវិទ្យា) នៅវិទ្យាល័យព្រះស៊ីហនុ ជាមួយនិងមិត្តនារី ជុំ ឌីវ៉ាត និស្សិតសាស្ត្រាចារ្យឆ្នាំទី២ (ភាសាបារាំង)ដែរ ។ ក្នុងឱកាសនោះ ថ្វីត្បិតតែមង្គលការបានជាន់លើការប្រឡងមធ្យមសិក្សាបត្រ


LE SYSTEME SCOLAIRE EN R.D.A.
Années de scolarité
Age
19 24
13 23
17 22
16 21
15 20
14 19
13 18
12 17
11 16
10 15
9 14
8 13
7 12
6 11
5 10
4 9
3 8
2 7
1 6
5
4
3
Ecole de spécialistes
Grand écoles
Uni-versité
Ecole secondaire du soir
Ecole secondaire d'entreprise (sans interruption de l'activité professionnelle
Faculté ouvrière et paysanne
Ecole de spécialistes
Cours propédeutique
Formation professionnelle
3 ans
2 ans
Ecole professionnelle
Classe spéciale (3 ans) avec baccalauréat
Stage dans la production (1 an)
Ecole sec. prolongée (12 cl.)
ECOLE SECONDAIRE D'ENSEIGNEMENT
GENERAL POLYTECHNIQUE DE 10 CLASSES
JARDIN D'ENFANTS


VIE PRATIQUE
Candidature au doctorat ès sciences
Hautes écoles (3 à 6 ans)
Ecoles secondaires pour les travailleurs (2 à 3 ans)
Ecoles secondaires d'enseignement général (3 ans)
Ecoles secondaires professionnelles (4 ans)
Ecoles professionnelles (2ans)
Centres de formation professionnelle et écoles d'apprentissage (1 à 3 ans)
Ecoles de base de 9 ans (de 6 à 15 ans — écoles obligatoires)
Ecoles maternelles (de 3 ans à 6 ans)
Crèches (de 3 mois à 3 ans)
Possibilités de passage à la vie pratique
Possibilités d'études ultérieures
Ecoles terminées par le baccalauréat

ទី១ ក៏ដោយ ក៏មិត្តជាច្រើនបានឆ្លៀតទៅសំដែងទឹកចិត្តមេត្រីរាប់អានដល់មិត្តយើងដែរ ដោយមិត្តខ្លះ (ស ពៅ, ប៉ែន ណារិទ្ធិ, គឹម ស៊ីយ៉ុង, ដោម ហ៊ិន, កុយ ផ្លួន, ឃាង ជ្លួន ជាដើម) បានទៅ ហើយត្រឡប់មកភ្នំពេញវិញទាំងយប់ផង ។

◙ នៅឯកំពង់ធំវិញ មិត្ត ម៉ម ណាង បានរៀបអាពាហ៍ពិពាហ៍ជាមួយនឹង កញ្ញា ជុំ ឡាំងហៀង កាលពីថ្ងៃ ២១ មិថុនា ១៩៦៤ ។ មិត្តតំណាងដែលផ្ញើពត៌មាននេះមកយើង ពុំបានពណ៌នាពីបរិយាកាសនៃពិធីទេ ប៉ុន្តែយើងជឿថាមិត្ត ស. ស. ១. ខាងកំពង់ធំ ក៏ដូចជាមិត្តខាងកំពង់ចាមដែរ មុខតែមិនភ្លេចភារៈខ្លួនទេ ហើយមិនខាននឹងទៅជួយអបអរសាទរគូស្វាមីភរិយាថ្មីឡើយ ។

◙ ម្យ៉ាងទៀត តាមដំណឹងល្ហិចល្ហៀងដែលយើងបានទទួលពីកំពង់ធំដដែលមក ឮថាមិត្ត អ៊ុំ ឈឿន នឹងមិត្ត យ៉ុង យ៉េន បាននាំគ្នាប្រុងប្រៀបខ្លួនជាស្រេច ដើម្បីនឹងឆ្លៀតពេលដ៏ប្រសើរនៃវិស្សមកាលនេះរៀបអាពាហ៍ពិពាហ៍ដែរ ។ យើងយល់ថានេះជាគំនិតដ៏ប្រសើរមួយ ដែលមិត្តនៅខេត្តឯទៀត ៗ គួរតែជួយរីករាយ ហើយប្រសិនបើត្រូវការ ក៏គួរតែលៃលកគិតគូរប្រើវិស្សមកាលនេះដែរ ។

◙ ប៉ុន្តែដំណឹងពីកំពង់ធំ មិនមែនសុទ្ធតែទាក់ទងនឹង អាពាហ៍ពិពាហ៍ដោយផ្ដាច់មុខនោះទេ ពីព្រោះមិត្តតំណាងបានឲ្យពត៌មានមកយើងថា មិត្ត ម៉ៅ សាមឿន នឹង តាន់ ហុកឃី (វិទ្យាល័យកំពង់ធំ) បន្ទាប់ពីបានព្យាយាមសិក្សាអស់ពេលជាយូរមកទើបនឹងបានបេះផ្លែផ្កា << មធ្យមសិក្សាបត្រ ភាគទី ១ >> ក្នុងសម័យខែឧសភា ១៩៦៤ នេះ ។

គណៈកម្មាធិការទាយកទទួលដំណឹងនេះដោយសាទរយ៉ាងក្រៃលែង ហើយសូមឆ្លៀតឱកាសនេះអំពាវនាវដល់មិត្តទាំងឡាយឲ្យខិតខំបណ្ដុះបណ្ដាលវប្បធម៌ទូទៅ ក៏ដូចជាវប្បធម៌វិជ្ជាជីវៈ នឹងចំណេះវិជ្ជារបស់ខ្លួន ឲ្យបានលូតលាស់កុំឈប់ឈរឲ្យសោះពីព្រោះ

ការសិក្សា ការបណ្ដុះបណ្ដាលវប្បធម៌របស់ខ្លួនគ្មានទីបញ្ចប់ទេ ហើយជនណាដែលយល់ថា «ប៉ុណ្ណឹងបានហើយ» ឬ «អាត្មាអញចេះតែជាងគេគ្មាននរណាដល់» នោះ មុខជានឹងក្លាយជាហួសសម័យ ហើយត្រូវគេសើចចំអកលេងជាមិនខាន ។

■ មិត្ត ជិន សុគន្ធ នៅអនុវិទ្យាល័យសួង នឹង កញ្ញា ហេង ស៊ីហៀង ទើបនឹងបានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា កាលពីថ្ងៃពុធ ១ កក្កដា ១៩៦៤ នេះ នៅទីស្នាក់ការនៃសមាគមសុរិយោដី នៅភ្នំពេញ ។ នៅក្នុងឱកាសដ៏រីករាយនោះ គេសង្កេតឃើញមិត្តខ្លះក្នុងគណៈកម្មាធិការនាយក មិត្តសាស្ត្រាចារ្យជាច្រើនមកពីសួង នឹងពីអនុវិទ្យាល័យនានា ហើយ នឹង ញាតិមិត្តជាច្រើនទៀត ។

■ ដំណឹងពីកំពង់ចាមតមកទៀតបានឲ្យដឹងថា កាលពីថ្ងៃ ៧ កក្កដា ១៩៦៤ នេះ មិត្ត យិម ម៉េង (វិទ្យាល័យព្រះសីហនុ) បានរៀបអាពាហ៍ពិពាហ៍ក្នុងបរិយាកាសយ៉ាងរីករាយ ។ មិត្តយើងជាច្រើនក៏បានទៅចូលប្រស្រ័យដែរ ។

ចំពោះមិត្តទាំងប៉ុន្មានដែលទើបនឹងមានគូស្រករថ្មីនេះ គណៈកម្មាធិការនាយកមានសេចក្ដីសោមនស្ស នឹងប្រសិទ្ធិជូននូវពរសព្ទសាធុការដ៏ប្រសើរសព្វបែបយ៉ាង ។ រីឯមិត្តដែលរៀប នឹង «មានផ្ទះសំបែង» ក្នុងវិស្សមកាលនេះក៏សូមឲ្យជួបប្រទះនូវសព្ទសាធុការពរដូចគ្នានេះដែរ ។

■ មិត្ត លឹម យូតិប នៃអនុវិទ្យាល័យកោះធំ (កណ្ដាល) ដែលបានព្យាយាមដុសខាត់វិជ្ជាខ្លួនដូចមិត្ត ម៉ៅ សាមឿន នឹង តាន់ ហ៊ុកយី នៅកំពង់ធំដែរ ទើបនឹងបានជាប់មធ្យមសិក្សាបត្រភាគទី ១ កាលពីសម័យខែឧសភានេះ ហើយនឹងចូលរៀននៅវិទ្យាស្ថានជាតិគរុកោសល្យនៅបវេសនកាលខាងមុខនេះ ។

■ ចំណែកឯមិត្ត យី យន់, ញ៉ុក បៃសិទ្ធិ នឹង ឈន អៀម នៃអនុវិទ្យាល័យសន្តិភាព (កំពង់ស្ពឺ) វិញ ទើបនឹងបានប្រឡងជាប់សញ្ញាបត្រជាន់ខ្ពស់សំរាប់បរិញ្ញាបត្រ

គណៈកម្មាធិការនាយក សូមប្រសិទ្ធិពរឲ្យមិត្តទាំងនេះបានសំរេចជោគជ័យជាអនេកប្បការនៅក្នុងការសិក្សារបស់ខ្លួនទៅអនាគត ។

◙ ម្យ៉ាងទៀត គណៈកម្មានាយកជឿថាសុខទុក្ខនៃមិត្តយើងក្តី លទ្ធផលនៃការសិក្សានៃមិត្តយើងក្តី ទីងបញ្ហាផ្សេងៗទៀតនៃជីវភាពមិត្តយើងក្តី ( មានអាពាហ៍ពិពាហ៍ គ្រោះថ្នាក់ជាដើម ) មិនមែនមានតែត្រឹមប៉ុណ្ណោះនាក់ទេ ហើយសូមអំពាវនាវក្នុងទីនេះម្តងទៀត ដល់មិត្តតំណាងណាដែលមិនទាន់បានផ្ញើសេចក្តីសុខទុក្ខរបស់មិត្ត ក្នុងសាលានិមួយៗរបស់ខ្លួនសូមឲ្យរួសរាន់ឡើង ។ តាមពិត ប្រសិនបើមិត្តតំណាងមិនឲ្យពត៌មានមកទេ គណៈកម្មាធិការនាយកហើយនឹង សមាជិកមិនអាចនឹងដឹងសុខទុក្ខគ្នាបានឡើយ ។ ព្រមជាមួយនេះ គណៈកម្មាធិការនាយកសូមថ្លែងសេចក្តីពេញចិត្តនឹងអំណរគុណចំពោះមិត្តតំណាងដែលបានយកចិត្តទុកដាក់ធ្វើខ្លួនឲ្យទៅជាសរសៃឈាមរត់យ៉ាងពិតប្រាកដរវាងគណៈកម្មាធិការនាយកហើយនឹងសមាជិក ។

★

# កំសាន្ត

## ការជជែកគ្នា

យប់ងងឹតណាស់ទៅហើយ ប៉ុន្តែក្មេង-ក្មេងទាំងឡាយជាកូនលោក ស៊ើរ៍ នៅតែជជែកគ្នាលេងទៀត ពីព្រោះល្ងាចនោះជាល្ងាចថ្ងៃសៅរ៍ ។ លោក ស៊ើរ៍ ត្រឡប់មកពីលេងកីឡាវិញ ឃើញក្នុងផ្ទះងងឹតឈឹងដូចនោះក៏កើតសៅម៉ង ហើយបន្ទោសកូនៗ ៖

– ចុះឯងរាល់គ្នាមិនឃើញងងឹតទេ បានជាគិតតែជជែកគ្នាដូចនេះ ?

– បាទ ព្រោះតែឃើញងងឹតហ្នឹងហើយតើប៉ា បានជាយើងខំជជែកគ្នា ព្រោះយើងឮអ្នកគ្រូប្រាប់យើងថា «តែជជែកគ្នា វាមុខតែចេញពន្លឺហើយ !»

# យើង នឹង យើងគ្នា



■ មិត្ត ស· សារិន្ទ (សាលា?)

បំពោះសេចក្ដីស្នើរបស់មិត្ត ឲ្យចុះបន្ថែមគោលគំនិតសំរាប់ធ្វើអត្ថាធិប្បាយប្រធានទិមួយៗ ពីក្រោយប្រធានទិមួយៗនោះ យើងយល់ឃើញថាជាគំនិតល្អមួយដែលយើងគួរតែបំពេញចិត្ត ។ ប៉ុន្តែប្រសិនបើយើងមានការខ្វះខាតក្នុងការនេះ នេះគឺពិតជាមកពីពេលវេលា និងអ្នកសរសេរ ។ ពេលណាមានឱកាសយើងនឹងសូមបំពេញបំណងរបស់មិត្តជាមិនខាន ដូចក្នុងលេខមួយនោះ យើងបានធ្វើអត្ថាធិប្បាយអំពីប្រធានប្រឡងចូលវិទ្យាស្ថានជាតិមួយ ស្ដីអំពី «ការៈកិច្ចនៃសាស្ត្រាចារ្យ» ។

■ មិត្ត អ៊ឹង គឹមសេង វិទ្យា. ព្រះសីហនុ

សូមថ្លែងអំណរគុណចំពោះអត្ថបទរបស់មិត្ត ស្ដីពីប្រទេសជាសមាជិកនៃ អ. ស. ប. ដែលយើងបានកែប្រែបន្តិចខ្លះដូចឃើញស្រាប់ ។

■ មិត្ត ប៉ែន ណារិត វិទ្យា. ព្រះសុរិយោវង្ស

ដោយក្នុងលេខនេះ មានអត្ថបទអំពីប្រវត្តិវិទ្យាច្រើនពេក យើងសូមអនុញ្ញាតទុកអត្ថបទរបស់មិត្តទៅលេខក្រោយៗទៀត ។ អំណរគុណដ៏ជ្រាលជ្រៅ ។

▣ មិត្ត ឈឹម សំណាង វិទ្យាល័យព្រះឧទ័យ

សូមអរគុណចំពោះអត្ថបទមិត្ត ។ លើកក្រោយប្រសិនបើមិត្តខិតខំសរសេរឲ្យបានវែងជាងនេះទៀត ជាការប្រសើរណាស់ ។

▣ មិត្ត សមាជិក ស. ស. ១.

ប្រសិនបើមិត្ត ឃើញមិត្តតំណាងក្នុងសាលាមិត្តមានការរវល់ជាប់ដៃខ្លាំងពេក ហើយមានការភ្លាំងភ្លាត់ខ្វះក្នុងកិច្ចការ សូមមិត្តមេត្តាជួយរំលឹកគ្នាផង រំលឹកជាមិត្តភាព ។

តាមធម្មតា មិត្តតំណាងដែលជាចាងហ្វាង ឬ នាយក ឬ សិក្សាធិការតែងមានការរវល់ច្រើនណាស់ ។ សូមមិត្តសមាជិកមេត្តាកុំមើលបំណាំ ដើម្បីឲ្យគ្រួសារយើងមានដំណើរទៅមុខដោយជៀសវាងវិបត្តិរួច ។ ការរំលឹកគ្នាទៅវិញទៅមកជាមិត្ត ជាការចាំបាច់ណាស់ ។

– ដូចជានៅពេលដាច់ខែ បើមិនឃើញតំណាងទារភាគទានប្រចាំខែទេ គួរតែរំលឹកឲ្យទារឡើង កុំឲ្យនៅជាន់ច្រើនឡើង ៗ ។ ដូចជាបាន ១ ត្រីមាសហើយ បើមិត្តតំណាងមិនទាន់បានផ្ញើភាគទានមកគណៈកម្មាធិការនាយកទេ គួរតែរំលឹកឡើង ។ សូមមិត្តជ្រាបថា កាលណាគណៈកម្មាធិការនាយកបានទទួលហើយ ឬ ក៏មិនទាន់បានទទួលទេ មិត្តអាចនឹងដឹងតាមទស្សនាវដ្ដី ឬ ព្រឹត្តិបត្រ (បើមិនទាន់ចុះ គឺមិនទាន់បានទទួលទេ) ។

– ដូចជានៅក្នុងសាលានោះ មានមិត្តមានទុក្ខធុរៈអ្វី (ឈឺថ្កាត់, គ្រោះថ្នាក់, សំពលកូន, . . .) គួរតែរំលឹកមិត្តតំណាងឲ្យចាត់គ្នាទៅជួយដៃជើងរួចហើយគួរតែរំលឹកឲ្យផ្ញើពត៌មានមកគណៈកម្មាធិការនាយក ។

– ដូចជា មានមិត្តមកព្យាបាលពេក ឬ ករិយាមកសំពលកូននៅភ្នំពេញ ឬ នៅខែត្រ គួរតែរំលឹកតំណាងឲ្យជូនដំណឹងមកគណៈកម្មាធិការនាយក ឬ ទៅតំណាង ស. ស. ១. នៅខែត្រ ដើម្បីឲ្យទៅជួយសាកសួរផង ។

◙ ឯមិត្តតំណាងដែលមានការត្អាំងត្អាត់ កាលបើបានទទួលសេចក្ដីរំលឹកហើយ ក៏គួរតែលៃលកយកចិត្តទុកដាក់ចាត់ចែងឲ្យបានរួសរាន់ផង ។

គណៈកម្មាធិការនាយកជឿថា អស់មិត្តដែលធ្លាប់តែចេះស្គាល់ទុក្ខធុរៈគ្នាជាដរាបរៀងមកហើយ មុខជានឹងខិតខំឲ្យបានកាន់តែជិតដល់ជាងទៀតជាមិនខាន ។

សូមអរគុណ

★

# កំសាន្ត

ម្ដងនោះ មានមនុស្សម្នាក់កំណាញ់ខ្លាំង ប៉ុន្តែល្ងើយ៉ាងក្រៃលែង ល្ងើមែនទែនទាល់តែមិនស្គាល់ថា ណាជាសណ្ដែកណាជាល្ង; ហើយបើកាលណាគេត្រូវការរាប់ចំនួនទារបស់គេ គេបញ្ចេញវាម្ដងពីរម្ដងពីរ ។

គាប់ជួនមួយថ្ងៃនោះ រាប់-រាប់ទៅខ្វះទាមួយ ។ អ្នកកំណាញ់កើតក្ដីមួម៉ៅ ខឹងក្រទេក្រោធនឹងដើងឈ្នួលរបស់គេ ហើយវាយដំប្រំបាក់គ្នាយ៉ាងខ្លាំង ។ លុះអស់ចិត្តហើយទើបគេបន្ទោសដើងឈ្នួលគេថា ៖

– ឯងបានធ្វើឲ្យបាត់ទាអញមួយ ត្រូវតែឯងទៅរកឯណាមកសងអញវិញឲ្យបាន ។

ថ្ងៃស្អែកឡើង ដើងឈ្នួលគិតស្រេចហើយក៏ទៅយកទាមួយមកកាប់ស៊ី ។ លុះដល់ពេលរាប់ទាម្ដងទៀត ចៅហ្វាយក៏បានឃើញថាទាមានចំនួនគ្រប់គួឡើងវិញ ។

ចៅហ្វាយសប្បាយចិត្តបំទមាត់មិនជិត ក៏និយាយប្រាប់អ្នកជិតខាងថា ៖

– អ្នកឯងឃើញទេ ដើងឈ្នួលខ្ញុំហ្នឹងបានតែលេងដៃក្ដៅទេ ទើបវាយកទាមកសង ។

(រឿងកូរ៉េ)

# ប្រាក់ចំណូលរបស់សមាគម ដែលបានទទួលក្រោយពីការបញ្ចេញទស្សនាវដ្ដី

## លេខ ១១-១២ គឺៈ

| | | | |
|---|---|---|---|
| វិទ្យាល័យ | ព្រះឧទ័យ | 8-1-64 | 944 រៀល |
| ,, | ព្រះមុនីវង្ស | 13-1-64 | 2.200 – |
| អនុវិទ្យាល័យ | ខ្សាច់កណ្ដាល | 17-1-64 | 780 – |
| ,, | ព្រែកសណ្ដែក | ,, | 1.090 – |
| វិទ្យាល័យ | ព្រះសុរាម្រឹត | 19-1-64 | 520 – |
| ,, | ព្រះសុរិយោវង្ស | 24-1-64 | 1.042 – |
| ,, | សង្គមរាស្ត្រនិយម | 25-1-64 | 1.200 – |
| អនុវិទ្យាល័យ | ទឹកខ្មៅ | 25-1-64 | 620 – |
| ,, | ក្រូចឆ្មារ | 5-2-64 | 1.700 – |
| ,, | ជ័យវរ្ម័នទី ៧ | ,, | 1.980 – |
| ,, | កំពង់ត្របែក | 11-2-64 | 1.670 – |
| ,, | ស្ទឹងត្រង់ | ,, | 460 – |
| ,, | ធន្ទបុញ្ញា | 19-2-64 | 3.300 – |
| ,, | ស្ទឹងត្រែង | 20-2-54 | 180 – |
| ,, | ស្គួង | ,, | 1.620 – |
| ,, | តាំង គោក | 26-2-64 | 1.080 – |
| វិទ្យាល័យ | ព្រះមុនីវង្ស | 5-3-64 | 3.000 – |
| ,, | ព្រះស៊ីសុវត្ថិ | ,, | 900 – |
| អនុវិទ្យាល័យ | ព្រះនរោត្តម | ,, | 1.200 – |
| ,, | សន្តិភាព (កំពង់ស្ពឺ) | 12-3-64 | 1.160 – |
| ,, | ឈូក | 26-3-64 | 900 – |
| ,, | ផែនការព្រះសីហនុ (កំពង់ចាម) | 26-3-64 | 760 – |
| វិទ្យាស្ថានជាតិ | គរុកោសល្យ | 31-3-64 | 2.000 – |
| អនុវិទ្យាល័យ | ពាមជីកង | 3-4-64 | 1.[illegible]60 – |
| វិទ្យាល័យ | ព្រះសុរិយោវង្ស | 21-4-64 | 1.109 – |
| ,, | ព្រះសុរាម្រឹត | 23-4-64 | 680 – |
| អនុវិទ្យាល័យ | ស្គន់ | ,, | 824 – |
| ,, | កោះធំ | 12-5-64 | 680 + 340 រ = 1.020 |
| វិទ្យាល័យ | ខ្មែរ – អង់គ្លេស | 15-5-64 | 540 រៀល |

| | | | |
|---|---|---|---|
| អនុវិទ្យាល័យ | ដីហែ | 28 - 5 - 64 | 2.080 រៀល |
| វិទ្យាល័យ | សង្គមរាស្ត្រនិយម | 4 - 6 - 64 | 900 – |
| ,, | ព្រះមុនីវង្ស | ,, | 2 800 – |
| ,, | កំពង់ធំ | 23 - 6 - 64 | 1.000 – |
| អនុវិទ្យាល័យ | កោះធំ | ,, | 340 – |
| ,, | ទឹកខ្មៅ | 25 - 6 - 64 | 680 – |
| ពុទ្ធិកវិទ្យាល័យ | ព្រះសុរាម្រឹត | ,, | 200 – |

*គណៈកម្មាធិការនាយក សូមអរគុណមិត្តតំណាងដែលបានបំពេញភារៈខ្លួនយ៉ាងទៀងទាត់ ក្នុងវិស័យហិរញ្ញវត្ថុនេះជាពន់ពេក ហើយសូមសង្ឃឹមថា មិត្តដែលនៅយឺតយ៉ាវនៅឡើយ គង់នឹងរួសរាន់ជាមិនខាន ។*

★

**5**

## *សូមមិត្តទាំងឡាយ មេត្តាចាប់អារម្មណ៍*

អំពីការជួយផ្តល់ពត៌មាន សុខទុក្ខនៃមិត្តយើង

ហើយនឹងអំពីអត្ថបទសំរាប់ទស្សនាវដ្តីយើងឲ្យមែនទែន ។



# វត្ថុបទ & ឯកសារ

## ១-ឯករាជ្យទីពីរ

បន្ទាប់ពីបានធ្វើបុណ្យខួបទីដប់រំលឹកឯករាជ្យនយោបាយមក ប្រជាជាតិខ្មែរបានសំរេចជាឯកច្ឆន្ទនឹងធ្វើបុជនីយកិច្ចមួយថ្មីទៀត ដើម្បីនឹងស្ដាបនានូវឯករាជ្យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

តាមពិត ចាប់តាំងពីខែវិច្ឆិកាឆ្នាំ ១៩៦៣ រៀងរហូតមក រាជរដ្ឋាភិបាល ក្រោមព្រះកិច្ចមគ្គុទ្ទេសន៍នៃព្រះប្រមុខរដ្ឋ បានដកហូតវិស័យសំខាន់ៗជាអាយុជីវិតពីកណ្ដាប់ដៃឯកជនមកឲ្យរដ្ឋកាន់កាប់ផ្ទាល់វិញ ដោយអនុលោមទៅតាមគោលការណ៍នៃផែនការដែលបានកំណត់ទុករួចមកហើយ ។ វិស័យជាវត្ថុចាប់ព្រះរាជហឫទ័យជាងគេគឺវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រោះថា បើការអនុវត្តប្រព្រឹត្តទៅប្រកបដោយជោគជ័យ នោះវិបត្តិសេដ្ឋកិច្ចអាចនឹងជៀសវាងបាន ហើយឱនភាពថវិកាក៏អាចនឹងបញ្ចប់បាន រីឯស្ថិរភាពនយោបាយនៃប្រទេស ហើយនិងស្ថិរភាពនៃតម្លៃអំពែក៏អាចនឹងរក្សាឲ្យគង់វង្សបានដែរ ។ ដូចនេះហើយបានជាវិធានការជាតូបនីយកម្មដំបូងអស់ បានធ្លាក់ទៅចំផ្នែកធនាគារ និងអាហរណ៍-នីហរណ៍ ហើយបានឈានតមកទៀតដល់ផ្នែកសុរាគារនិងក្រុមហ៊ុនធានារ៉ាប់រង ។ ប៉ុន្តែអានុភាពៈជោគជ័យនៃការកែទំរង់នេះ មិនបិតនៅតែក្នុងក្របខណ្ឌនៃសេដ្ឋកិច្ចនិងហិរញ្ញវត្ថុប៉ុណ្ណោះទេ, ឥទ្ធិពលនេះអាចហៀរហូរចូលទៅដល់ផ្នែកនយោបាយ វប្បធម៌និងសង្គមកិច្ចទៀតៈ ហើយជាពិសេស គឺអាចនឹងលើកឋានៈជីវភាពនៃប្រជាពលរដ្ឋទៀតផង ។

យ៉ាងនេះហើយបានជាប្រជាករទទួលនយោបាយកែទម្រង់នេះដោយសោមនស្សសាទរ ហើយបានស្ម័គ្រចិត្តនាំគ្នាទៅសំដែងមហាបាតុកម្មមួយយ៉ាងគគ្រឹកគគ្រេង ក្នុងពេលនោះ នៅមុខព្រះបរមរាជវាំង ដើម្បីនឹងឧបត្ថម្ភយ៉ាងម៉ឺងម៉ាត់នូវមាគ៌ាថ្មីនេះផង ដើម្បីនឹងសំដែងនូវមហាករុណាធិគុណរបស់ខ្លួនចំពោះព្រះអគ្គមគ្គុទ្ទេសក៍ផង ហើយព្រមជាមួយនេះក៏ដើម្បីនឹងប្រឆាំងដាច់អហំការនឹងសត្រូវ នៃមាគ៌ាកែទម្រង់នេះផងដែរ ។

⊡

## ២ – សេដ្ឋកិច្ចនឹងការសិក្សា

សេដ្ឋកិច្ចនឹងការសិក្សាជាវិស័យពីរដ៏សំខាន់ ដែលជាប់ទាក់ទងគ្នាយ៉ាងជិតស្និទ្ធ ហើយមានអានុភាពលើគ្នាទៅវិញទៅមកយ៉ាងធំធេង ។ ហេតុនេះហើយបានជា ដើម្បីនឹងសំរេចនូវឯករាជ្យសេដ្ឋកិច្ច ដែលព្រះអង្គទ្រង់សព្វព្រះរាជហឫទ័យលើកឡើងកាលពីខែវិច្ឆិកា ឆ្នាំ ១៩៦៣ នេះ ព្រះបិតាសាមគ្គីភាពជាតិទ្រង់បានប្រទាននូវសន្និសីទមួយពោរពេញទៅដោយសារៈសំខាន់ ស្តីពីការកែទម្រង់សិក្សាធិការ ប្រយោជន៍នឹងឲ្យមានដំណើរស្របទៅតាមគោលបំណងនៃការកែទម្រង់សេដ្ឋកិច្ចនេះ ។

សេដ្ឋកិច្ចជាកត្តាសំខាន់បំផុត ដែលសំរេចអំពីការវិវត្តន៍ល្អគលាស់ ឬការថែមថយនៃនយោបាយសង្គមកិច្ចនឹងវប្បធម៌ ។ យ៉ាងណាមិញ បើប្រទេសណាមួយជៀសវាងមិនផុតពីវិបត្តិសេដ្ឋកិច្ចទេ ឬក៏ជួបប្រទះតែនឹងឱនភាពហិរញ្ញវត្ថុជាញឹកញាប់ទេ តើរដ្ឋាភិបាលនៃប្រទេសនោះ មានថវិកាឯណានឹងអនុវត្តផែនការសិក្សាធិការជាតិរបស់ខ្លួនបាន ? តើប្រជាពលរដ្ឋនៃប្រទេសនោះ មានប្រាក់កាសឯណានឹងធ្វើវិភាគទានស្ម័គ្រចិត្តដល់រដ្ឋបាន ? ក្នុងករណីនេះ អាគារសិក្សាក៏ខ្វះខាត សម្ភារបរិក្ខារក៏មិនគ្រប់គ្រាន់ ឯលទ្ធផលនៃការសិក្សាទៀតសោត ក៏បានដោយស្តួចស្តើងជាអតិបរមា ហើយយុវជនមួយភាគដែលជាកម្លាំងអនាគត ក៏ត្រូវបិតនៅក្រៅសាលាទៀត ។ ចំណែកឯការសិក្សាវិញ ក៏

ជាកត្តាមួយសំខាន់ណាស់ដែរក្នុងការទ្រទ្រង់ ឬបន្ទាប់វិស័យសេដ្ឋកិច្ច ។ ប្រសិនបើសិក្សាធិការមានគោលការណ៍ នឹងការរៀបចំច្បាស់លាស់ស្របតាមសភាពការណ៍នឹងការត្រូវការរបស់ប្រទេស នោះយុវជនដែលជាកម្លាំងមួយផ្នែកពោរពេញទៅដោយថាមពល មុខតែនឹងជួយរួមចំណែកជ្រោមជ្រែងសេដ្ឋកិច្ចឲ្យបានស្គាល់នូវសម្បូរណភាពជាប្រាកដ ។ ហេតុនេះហើយបានជាក្នុងព្រះរាជសន្និសីទនោះ សម្តេចព្រះឧបយុវរាជទ្រង់បានគូសនូវមាគ៌ាធំៗ ដែលនឹងត្រូវអនុវត្តក្នុងកម្មវិធីសិក្សា ដោយទ្រង់បានណែនាំឲ្យការសិក្សាក្លាយពីការសិក្សាធ្វើនាម៉ឺនទៅជាការសិក្សាដើម្បីធ្វើជាអ្នកបច្ចេកទេស ទៅជាការសិក្សាដើម្បីចេះវិជ្ជាជីវៈសំរាប់រស់នៅ ទៅជាការសិក្សាបង្កើនផល ពោលគឺទៅជាការសិក្សាបណ្តុះសមត្ថភាព ដើម្បីរួមចំណែកស្ថាបនាសេដ្ឋកិច្ចជាតិឲ្យសំរេចគោលបំណងលើកឋានៈជីវភាពមហាជនកម្មករកសិករនឹងពលករទូទៅឲ្យបានយ៉ាងជាក់ស្តែង ។

◘

សូមមិត្តជ្រួតជ្រាបថា:

★ **ការកែទំរង់សិក្សាធិការ** ដែលសម្តេចឪ ទ្រង់សព្វព្រះរាជហឫទ័យត្រួសត្រាយក្នុងពេលថ្មីៗនេះ ជាកត្តាមួយសំខាន់ក្នុងការធ្វើឲ្យការកែទំរង់សេដ្ឋកិច្ច-ហិរញ្ញវត្ថុមានល្បឿនទៅមុខ ។

★ **ឯជោគជ័យនៃការកែទំរង់សេដ្ឋកិច្ច-ហិរញ្ញវត្ថុ** នេះជាការធានារ៉ាប់រង នឹងជាមូលដ្ឋានទ្រទ្រង់នូវឯករាជ្យនយោបាយរបស់យើង ។

★ **ដូចនេះសូមមិត្តឧបត្ថម្ភយ៉ាងសកម្មបំផុត** ឲ្យព្រះរាជតំរិះកែទំរង់សិក្សាធិការនេះបានសំរេចជោគជ័យជាអតិបរមា តាមសមត្ថភាពរៀងៗខ្លួនរបស់មិត្ត ។

**histoire**

## Liste des Etats membres de l'organisation des Nations-Unies classées par continent.

| Nom du pays | Capitale | Superficie (km2) | Population (Dernière estimation officielle). | Date d'admission à l'O.N.U. |
|---|---|---|---|---|
| **en AFRIQUE :** | | | | |
| 1. République Arabe Unie | Le Caire | 1.000.000 | 26.858.900 | 24-10-1945 |
| 2 Libéria | Monrovia | 111.370 | 1.290.000 | 2-11-1945 |
| 3. Afrique du Sud | Le Cap | 1.223.409 | 16.236.000 | 7-11-1945 |
| 4. Ethiopie | Addis Abeba | 1.184.320 | 20.000.000 | 13-11-1945 |
| 5. Libye | Tripoli | 1.759.540 | 1.216.000 | 14-12-1955 |
| 6. Maroc | Rabat | 443.680 | 11.925.000 | 12-11-1956 |
| 7. Soudan | Khartoum | 2.505.823 | 12 470.000 | — id — |
| 8. Tunisie | Tunis | 125 180 | 4 254.200 | — id — |
| 9. Ghana | Accra | 237.873 | 6 943 000 | 8-3-1957 |
| 10. Guinée | Conakry | 245.857 | 3.000 000 | 12-12-1958 |
| 11. Cameroun | Douala | 475.442 | 4.097.000 | 20-9 1960 |
| 12. Congo | Brazzaville | 342.000 | 90.000 | — id — |
| 13. Congo | Léopoldville | 2 345 409 | 14.797 000 | — id — |
| 14 Côte d'Ivoire | Abidjan | 322.463 | 3.300.000 | — id — |
| 15. Dahomey | Porto-Novo | 115.762 | 2.050.000 | — id — |
| 16. Gabon | Libreville | 267.000 | 447 880 | — id — |
| 17. Haute Volta | Ouagadougou | 274.200 | 4.404.200 | — id — |
| 18. Madagascar | Tananarive | 595.790 | 5.577.000 | — id — |
| 19. Niger | Niamey | 1.188.794 | 3 112.000 | — id — |
| 20. République Centrafricaine | Bangui | 617.000 | 1 227.000 | — id — |
| 21. Somalie | Mogadiscio | 637.661 | 2.030.000 | — id — |
| 22. Tchad | Fort Lamy | 1.284.000 | 2.680 000 | - id — |
| 23. Togo | Lomé | 56 600 | 1 539.000 | id — |
| 24. Sénégal | Dakar | 197.161 | 2.980 000 | 28-9-1960 |
| 25. Mali | Bamako | 1.204.021 | 4.100.000 | — id — |
| 26. Nigéria | Lagos | 923.772 | 39.473.000 | 7-10-1960 |
| 27. Sierra Leone | Freetown | 72 326 | 2.450.000 | 27-9-1961 |
| 28. Mauritanie | Nouakchott | 1.035.805 | 726.616 | 27-10-1961 |
| 29. Tanganyika | Das-es-Saalam | 937.061 | 9 560.400 | 14-12-1961 |
| 30. Burundi | Usumbura | 27.834 | 2 234.141 | 18-9-1962 |
| 31. Rwanda | Bukavu | 26.338 | 2.694 749 | — id — |
| 32. Algérie | Alger | 2.381.741 | 10.784.269 | 8-10-1962 |
| 33. Ouganda | Entebbe | 239.640 | 6 844 600 | 25-10-1962 |
| **en AMÉRIQUE :** | | | | |
| 34. Argentine | Buenos Aires | 2 776.656 | 21.247.420 | 24-10-1945 |
| 35. Brésil | Brasilia | 8.511.965 | 75.271.000 | — id — |
| 36. Chili | Santiago | 741.767 | 8 050.259 | — id — |
| 37. Cuba | La Havane | 114.524 | 7 068.451 | — id — |
| 38. Etats — Unis | Washington | 9.363.389 | 188.062 000 | -- id — |
| 39. Haïti | Port du Prince | 27.750 | 4.345 946 | id — |
| 40. Nicaragua | Managua | 148 000 | 1.551.688 | — id |
| 41. Paraguay | Asuncion | 406 752 | 1.857.000 | — id — |
| 42 République Dominicaine Trujillo | Cindad | 48.734 | 3.204.957 | — id — |
| 43. Salvador | San Salvador | 21 393 | 2 759 010 | id — |
| 44. Pérou | Santiago | 1 285.215 | 10 364 620 | 31-10 1945 |
| 45. Costa Rica | San tosé | 50.700 | 1.295 766 | 2-11-1945 |
| 46. Colombie | Bogota | 1.138.338 | 14.768.510 | 5-11-1945 |
| 47. Mexique | Mexico | 1.972.546 | 37 233.227 | 7-11-1945 |
| 48. Canada | Ottawa | 9.976 177 | 18.600.000 | 9-11-1945 |
| 49. Panama | Panama | 74.470 | 1.138.880 | 13-11-1945 |

| | | | | |
|---|---|---|---|---|
| 50. Bolivie | La Paz | 1.098 581 | 3.548.700 | 14-11-1945 |
| 51 Venezuela | Caracas | 912 050 | 7.788.494 | 15-11-1945 |
| 52. Gualemala | Guatemala | 108 889 | 3.979.789 | 21-11-1945 |
| 53. Honduras | Tegucigalpa | 112.088 | 1.949.643 | 17 12 1945 |
| 54. Uruguay | Montevidéo | 186.926 | 2.845.734 | 18-12-1945 |
| 55. Equateur | Quito | 270.670 | 4.578.800 | 21-12-1945 |
| 56. Jamaïque | Kingston | 11.425 | 1.641.459 | 18-9-1962 |
| 57. Trinité et Tobago | Port of spain | 5.128 | 859.250 | — id — |

**en ASIE :**

| | | | | |
|---|---|---|---|---|
| 58. Turquie | Ankara | 780.576 | 29 417 580 | 21-10-1945 |
| 59. Arabie Saoudite | La Mecque | 1 600.000 | 6.036.400 | — id — |
| 60. Chine | Pékin | 9.596.961 | 656.220 250 | — id — |
| 61. Iran | Téhéran | 1 648.000 | 21.748 000 | — id — |
| 62. Liban | Beyrouth | 10 400 | 1.645.813 | — id — |
| 63 Philippines | Manille | 299.681 | 30.047.000 | — id — |
| 64. Syrie | Damas | 184.479 | 4.555.267 | — id — |
| 65. Inde | New Delhi | 3.042.794 | 434 884 939 | 30-10-1945 |
| 66. Irak | Bagdad | 448.742 | 7.263·000 | 21-12-1945 |
| 67 Afghanistan | Kaboul | 650.000 | 13.800.000 | 19-11-1946 |
| 68. Thaïlande | Bangkok | 514.000 | 28 000.000 | 16-12-1946 |
| 69. Pakistan | Rawalpindi | 946.716 | 96.558.121 | 30-9-1947 |
| 70. Yémen | Sanaa | 195.000 | 5.000 000 | — id — |
| 71. Birmanie | Rangoon | 678 033 | 22 342.000 | 19-4-1948 |
| 72 Israel | Tel-Aviv | 20.700 | 2.326.000 | 11-5-1949 |
| 73. Indonésie | Djakarta | 1.491.564 | 96.750.000 | 28-9-1950 |
| 74. Cambodge | Phnom-Penh | 180.000 | 5.748.842 | 14-12-1955 |
| 75. Ceylan | Colombo | 65.610 | 10.167.000 | — id — |
| 76. Jordanie | Amman | 96.610 | 1.690.123 | — id — |
| 77 Laos | Vientiane | 236.800 | 1.881.603 | — id — |
| 78. Népal | Katmandou | 140.798 | 9 387.661 | — id — |
| 79. Japon | Tokyo | 369.661 | 95.260.000 | 16 12-1956 |
| 80. Fédération de Malaisie | Kuala Lumpur | 131.313 | 7.250.289 | 17-9 1957 |
| 81. Chypre | Nicosie | 9.251 | 583.000 | 20-9 1960 |
| 82. Mongolie | Oulan Bator | 1.535.500 | 998.100 | 27-10-1961 |
| 83. Koweït | El koweït | 15.540 | 321.621 | 14-5-1963 |

**en EUROPE :**

| | | | | |
|---|---|---|---|---|
| 84. Danemark | Copenhague | 43.043 | 4.617.000 | 24-10-1945 |
| 85. France | Paris | 551.208 | 42.710.000 | — id — |
| 86 Luxembourg | Luxembourg | 2 586 | 319.526 | id — |
| 87. Pologne | Varsovie | 311.730 | 30.406.000 | — id — |
| 88. République socialiste soviétique de Biélorussie | Minsh | 207.600 | 8 270.300 | -- id — |
| 89. R S S. d'Ukraine | Kiev | 601.000 | 43.527.000 | — id — |
| 90. Royaume-Uni | Londres | 244.030 | 53.441.000 | — id — |
| 91. Tchécoslovaquie | Prague | 127.793 | 13.856.000 | — id — |
| 92. Union des Républiques socialistes soviétiques (1) | Moscou | 22.402.200 | 221 465 000 | - id — |
| 93. Yougoslavie | Belgrade | 255.804 | 18.941.000 | - id — |
| 94. Grèce | Athènes | 130.918 | 8.433.000 | 25-10-1945 |
| 95. Norvège | Oslo | 323.917 | 3.626.000 | 27-11-1945 |
| 96. Pays-Bas | Amsterdam | 33.612 | 11.81.6039 | 10-12-1945 |
| 97. Belgique | Bruxelles | 30.507 | 9.228.729 | 27-12-1945 |

1— Y compris la R. S. S. de Biélorussie et la R. S. S. d'Ukraine :

| | | | | | |
|---|---|---|---|---|---|
| 98. | Islande | Reykjavik | 103.000 | 180 058 | 19 - 11 - 1946 |
| 99. | Suède | Stockholm | 449.793 | 7.542.459 | — id — |
| 100. | H ngrie | Budapest | 93.031 | 10.071.000 | 14 - 10 - 1955 |
| 101. | Albanie | Tirana | 28.748 | 1.660.100 | 14 - 12 - 1955 |
| 102. | Autriche | Vienne | 83.849 | 7.080 600 | — id — |
| 103. | Bulgarie | Sofia | 110.669 | 7.580.700 | — id --- |
| 104. | Espagne | Madrid | 504.748 | 30.816.907 | — id |
| 105. | Finlande | Helsinki | 337.009 | 4.522.000 | — id – |
| 106. | Irlande | Dublin | 70.280 | 2 814.703 | -- id — |
| 107. | Italie | Rome | 301 225 | 49 881 000 | — id — |
| 108. | Portugal | Lisbonne | 91.531 | 9.298.200 | — id – |
| 109. | Roumanie | Bucarest | 237.500 | 18.566.932 | – id — |

**en OCEANIE :**

| | | | | | |
|---|---|---|---|---|---|
| 110. | Nouvelle - Zélande | Wellington | 268.676 | 2.498 441 | 24 - 10 - 1945 |
| 111. | Australie | Canberra | 7.704.159 | 10.705.100 | 1 - 11 - 1945 |

■


សូមមិត្តប្រយ័ត្ន៖ បារី ២០ រាល់ថ្ងៃ... ខេចអាយុ ៥ ឆ្នាំ!

ការអង្កេតមួយដែលវេជ្ជបណ្ឌិតហាមម៉ុន និង ហ៊ាន (Hammond, Horn) បានធ្វើអំពីមនុស្ស ១៨៨.០០០ នាក់ អាយុពី ៥០ ទៅ ៧០ ឆ្នាំ ទើបនឹងបានបង្ហាញលទ្ធផលថា ការប្រើបារីរាល់ថ្ងៃនឹងនាំឲ្យខេចអាយុអស់ ៥ ឆ្នាំ ។

ដូចនេះ ប្រសិនបើមិត្តមិនមែនជាបេក្ខជនខាងអត្តឃាដកម្ម ឬ ខាងអនិច្ចកម្មបន្តិចម្តងៗនេះទេ ចូរមិត្តបំបាត់ការប្រើថ្នាំជក់ទៅ ។ មានអ្នកជក់ដែលចាស់ជាច្រើនបានរួបរួមគ្នា ដើម្បីនឹងប្រាប់ដល់មិត្តនូវរបៀបដែលបានធ្វើឲ្យគេលែងជក់បារីយ៉ាងឆាប់រហ័ស និងយ៉ាងជាប់ខាតផង ។

ដើម្បីនឹងដកផលប្រយោជន៍ពីការពិសោធន៍ខាងលើនេះ មកធ្វើជាប្រយោជន៍មិត្ត មិត្តគ្រាន់តែសរសេរទៅអាសយដ្ឋានខាងក្រោមនេះ ក៏ជាការស្រេចទៅហើយ ហើយអ្នកនឹងទទួលនូវសេចក្តីពន្យល់ដោយឥតបង់ថ្លៃ ។

រឿងនេះនឹងធ្វើឲ្យមិត្តបានអាយុវែង ៥ ឆ្នាំថែមទៀត ។

Institut de défense contre les méfaits du tabac,
Service S. 1, 26, rue St-Charles, Paris (15e)

**Quelques faits historiques sur le tracé des frontières**

# ENTRE LE CAMBODGE, LE LAOS ET LE VIET-NAM

**histoire**

Avec le très haut accord de Samdech Chef de l'Etat, le «Neak Cheat Niyum» publie aujourd'hui un résumé des recherches entreprises par Sahachivin Sarinn Chhak sur les frontières actuelles du Royaume. Il convient de rendre hommage au travail de bénédiction auquel s'est livré notre ami Sarinn Chhak, juriste de talent et d'une conscience au-delà de tout éloge, qui depuis plusieurs mois dépouille les archives du protectorat français déposées à Paris.

Notre seul but en révélant des textes enfouis dans des dossiers poussièreux depuis plusieurs décades est de montrer dans quelle mesure le *Cambodge fut spolié par la France, au profit du Laos et du Viet-Nam, d'une* partie de ses territoires et de réduire à néant les prétentions injustifiables des Gouvernements de Saigon et de Vientiane. L'opinion internationnale pourra juger combien est criminelle et insensée l'attitude de ceux qui nous refusent le droit de survivre dans nos frontières actuelles bien en deçà de celles auxquelles nous serions pleinement habilités à prétendre.

Il convient d'admettre, en effet, qu'en proposant de geler ses frontières «de fait» consacrées par les accords de Genève de 1954, le Cambodge consent un sacrifice extrêmement douleureux. Mais il apparaît que nos voisins sont plus soucieux de faire appuyer leur annexionnisme à nos dépens par la force américaine et les menaces que de recourir au droit international.

Paris le 29 Février 1964

**Samdech Sahachivin,**

J'ai très respectueusement l'honneur de porter à la Haute connaissance de Votre Altesse Royale ce qui suit :

Dans les premiers jours de Janvier dernier j'ai adressé à Son Excellence Samdech Véang pour être soumis au Haut examen de Votre Altesse Royale un document manuscrit contenant le résultat de mes recherches sur la frontière de l'Est.

Le texte étant assez long (plus de cent pages), je me permets très respectueusement d'en relater ci-après le résumé.

1.— *Résultat des recherches :*

*A.— Les faits :*

Pour faciliter l'examen de la question, celle-ci sera présentée dans l'ordre Nord-Sud, c'est-à-dire à partir du Laos vers la mer.

1.— *Frontière avec le royaume du Bassac.*

Le territoire cambodgien s'étendait *au-delà du Tonlé Répou*. La demande de restitution de l'ensemble ou plutôt la revendication pour sa rétrocession a été formulée en 1893 par la France au nom de Sa Majesté Norodom.

Après la restitution par le Siam de ce territoire cambodgien, le Gouverneur Général de l'Indochine, sous consultation ni avec Sa Majesté le Roi, ni avec le Résident Supérieur au Camdodge, a fixé *arbitrairement* le Tonlé Répou comme frontière entre le Cambodge et le Royaume du Bassac. Cet acte a amputé le Cambodge de quelques «muongs» situés au-delà du Tonlé Répou.

2.— *Frontière du côté de Stung-Trèng*

*D'après plusieurs écrits, la région englobant Stung-Tréng, Khong et Attopeu relevait de la souveraineté du Roi du Cambodge.* Elle a été spoliée par la suite par la Cour de Bangkok.

En 1893, la France a présenté la revendication sur cette région au nom de Sa Majesté Norodom. Mais après sa restitution par le Siam, ce territoire a été administré d'abord par le Gouvernement de la Cochinchine, ensuite par le Résident Supérieur du Bas-Laos. Ce dernier a en 1898, *extrait de la province de Stung Trèng*, une portion de son territoire, pour constituer le commissariat de Darlac, lequel commissariat fut rattaché en 1904 à la Résidence Supérieure de l'Annam et en 1929 au royaume d'Annam.

Donc *le territoire du Darlac, statutairement cambodgien car il faisait partie de Stung Trèng*, fut annexé définitivement à l'Annam à cause des mesures arbitraires et fantaisistes prises par des administrateurs français, bien qu'un membre du Conseil d Etat expédié spécialement de Paris pour enquêter sur cette affaire eût conclu à l'absence de droits, ni de la France, ni de l'Annam, sur ce territoire.

3.— *Frontière dans la région Kratié, Kg. Cham*

Un arrêté du Gouverneur de la Cochinchine a explicitement reconnu que les cantons cambodgiens de Cuu Anh et Thanh Anh (au-delà de Loc Ninh) et les cantons Stiengs de Loc Ninh et Phuoc Lê furent rattachés au huven de «Can Lê» (c'est pour désigner Tonlé) en 1893, dans le but de faciliter la réquisition de main d'œuvre très rare dans cette région pour la construction de la route Bienhao — Thudaumot - Kratié.

De nombreux documents officiels attestent que les cantons de Loc-Ninh et Phuoc-Lê présentés comme habités par des Stiengs étaient *peuplés en forte majorité de Cambodgiens*

L'annexion arbitraire par le Gouverneur de la Cochinchine de ces *4 cantons khmers* donna lieu à plusieurs insurrections de la part de leurs habitants, et à des vives, sévères et multiples *protestations du Résident Supérieur au Cambodge*.

*Les cartes éditées avant 1903 portaient toutes Loc Ninh et Phuoc Lê en territoire cambodgien.*

Ce n'est qu'en 1914 qu'un arrêté du Gouverneur Général fut pris pour inclure définitivement ces deux cantons dans la Cochinchine.

4.— *Frontière de Tay-Ninh.*

Cette portion fut délimitée la première, en 1869-70. Avant la délimitation, toute la région située au Nord du poste de Tay-Ninh fut habitée presque exclusivement par des Cambodgiens. De nombreux rapports sur la révolte de Poucombo le confirment.

Plusieurs correspondances officielles confirment l'amputation par le Gouverneur de Cochinchine, *au détriment du Cambodge* de plusieurs sroks : *Chong Bodèn, Beng Chrum, Srok Tranh* et des *territoires compris dans l'enclave formée par les deux Vaïco.*

5.— *Frontière du côté de Hatien.*

Deux communes, celles de *Koh Chanloh* et de *Saky* que la délimitation de 1876 a comprises en territoire cambodgien nous furent *enlevées, en fait en* 1893 par l'administrateur de Hatien qui avait, pour justifier son acte, imaginé un prétendu déplacement de la ligne télégraphique servant de frontière pendant l'insurrection de 1884. Cette manœuvre se trouve mise à nu par plusieurs lettres de *A. Leclerc.* alors Résident de France à Kampot.

Bien que la thèse de déplacement de frontière fut combattue par une vérification effectuée conjointement par les autorités de Hatien et celles de Kampot, le Gouverneur Général de l'Indochine prit en 1914 un arrêté pour annexer à la Cochinchine les deux communes précitées, après avoir fait valoir l'existence des droits des Annamites sur ces Khums, qu'auraient attestés des documents annamites.

6.— *Les îles.*

La propriété de ces îles fut revendiquée réciproquement par les autorités françaises de la Cochinchine et par celles du Cambodge.

Les autorités de la Cochinchine se basaient sur l'existence sur ces îles de pêcheurs annamites et sur l'exercice par elles de l'administration.

Les autorités françaises du Cambodge répondirent que les Annamites n'étaient pas les seuls habitants de ces îles et qu'il y avait aussi plusieurs Chams et Chinois venant de Kampot pour s'y livrer à l'agriculture.

Quand à l'argument fondé sur l'exercice de l'administration, nous pouvons répondre que cette administration consistait simplement dans l'existence de poste de douane à la pointe de Samit. Or, depuis 1884, le Gouvernement Général de l'Indochine s'attribuaient tous les pouvoirs en matière de douane non seulement sur les îles du Golfe du Siam mais sur tous les pays de l'ancienne Indochine française. S'il fallait admettre que là où il existait des postes de douane, le territoire doit être considéré comme administré par la Cochinchine, on en arriverait à cette conclusion que tous les pays de l'ancienne Indochine française étaient administrés par la Cochinchine !!

B — *Points juridiques.*

Deux arguments juridiques semblent pouvoir être adoptés pour remettre en cause la frontière de l'Est.

1.— *Frontière administrative.*

La délimitation a été effectée, soit *unilatéralement* par le Gouvernement Général de l'Indochine, soit entre le protégé et le protecteur qui jouait le double rôle de *juge et partie.*

*Les deux parties ne sont pas placées sur un pied d'égalité,* condition requise pour que les accords revêtent le caractère d'accords internationaux.

Comme il s'agit d'une *frontière administrative,* il importe pour qu'elle devienne frontière internationale, que les deux pays intéressés l'approuvent après leur accession à l'indépendance.

2.— *Violation du droit des peuples à disposer d'eux-mêmes.*

Les insurrections qui eurent lieu après l'annexion des quatre cantons du côté de Loc-Ninh les protestations que souleva le Snang Mê qui avait l'administration de Beng-Chrum (du côté de Tay Ning) marquent le refus des populations intéressées d'accepter les annexions opérées. Le Gouverneur de la Cochinchine et par

la suite le Gouverneur Général de l'Indochine avaient donc *violé le principe des peuples à disposer d'eux-mêmes*, principe dont Napoléon III fut le promoteur et qui était universel dans la 2e moitié du 19e siècle.

II — *Opinions des universitaires français.*

Je me permets très respectueusement de rapporter à Votre Altesse Royale l'opinion de M. le Professeur Reuter.

— Le 5 Février dernier, au moment de la soutenance de mon mémoire pour le diplôme d'études supérieures, M. le Professeur Reuter m'a détaché de l'ensemble des candidats et m'a fait venir dans une salle où j'étais en tête-à-tête avec lui. Il prononça en particulier ces paroles : « Votre travail sur la frontière de l'Est nous accable profondément. Il faut avouer qu'on a l'impression que si la France s'était employée pour récupérer les territoires cambodgiens du côté de l'Ouest, pour ses intérêts naturellement, par contre elle grignotait par petits morceaux le Cambodge, du côté de l'Est, au profit de la Cochinchine ». Je l'ai remercié de sa sincérité.

J'ai l'impression que M. le Professeur Reuter a communiqué son opinion à quelques uns de ses collègues et en particulier à M. Pinto et à M. Imbert qui connaissent bien nos problèmes, et même à certaines personnalités du Quai d'Orsay dont il est le jurisconsulte adjoint.

Au cours d'un dîner offert le 10 Février dernier par S. E. Pho Prœung en l'honneur de S. E. M. Argold, parlant de nos relations avec le Sud-Viet-nam, M. Manach a prononcé devant S. E. Pho Prœung et S. E. Truong Cang que « les Sud-Viet-namiens (1) renonceront à la revendication sur les îles ».

o O o

Je me permets très respectueusement de prier Votre Altesse Royale de daigner m'excuser de la longueur de cette lettre, qui Lui occasionnera une perte de son temps si précieux pour la patrie. Mais je m'estime défaillant de ma part si je ne rends pas compte à Votre Altesse Royale des détails de ma mission qui constitue pour mois une marque de très Haute confiance que Votre Altesse Royale a daigné accorder à l'un de Ses humbles Sahachivin, et la meilleure récompense.

J'ai l'honneur d'être,

Samdech Sahachivin,

de Votre Altesse Royale,

le très humble et très dévoué serviteur.

**Sarin Chhak**

